# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍

## កិច្ចប្រជុំរួមប្រចាំខែមករា របស់អគ្គលេខាធិការដ្ឋាន



**ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧**

**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង០៩:០០នាទីព្រឹក នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមន្ត្រី បុគ្គលិកទាំងអស់ប្រចាំខែមករា ឆ្នាំ២០១៧ ដែលដឹកនាំការប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមានៈ អគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និង មន្ត្រី បុគ្គលិកទាំងអស់ចំនួន ៥៨ នាក់ ។

**អវត្តមានៈ**

១-លោកវេជ្ជ. ហួត សេរីរដ្ឋ (ច្បាប់)

២-លោកវេជ្ជ. រស់ សីលវ៉ាត់ (រៀនសាលាភូមិន្ទរដ្ឋបាល)

**គោលបំណងនៃកិច្ចប្រជុំនេះ មាន ៖**

១-ការងារបច្ចេកទេស

២-ការងាររដ្ឋបាល និង ការងារផ្សេងៗទៀត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបពីគោលបំណងនៃកិច្ចប្រជុំ ដោយផ្តោតទៅលើការងាររដ្ឋបាល ការងារបច្ចេកទេស និងផ្តល់ឱកាសដល់មន្ត្រី បុគ្គលិកលើកឡើងនិងពិភាក្សាដោះស្រាយពីបញ្ហាដែលកើតមានឡើងក្នុងរយៈនៃការបំពេញការងារកន្លងមក។

**១. ការងាររដ្ឋបាល ៖**

បន្ទាប់ពីបានផ្ទៀងផ្ទាត់មួយចំណុចម្តងៗ លើសកម្មភាពអនុវត្តក្នុងខែមុនរួចមក ឯកឧត្តមប្រធានអង្គប្រជុំ ឱ្យនាយកដ្ឋាននីមួយៗរាយការណ៍ពីសកម្មភាពដែលបានអនុវត្តៈ

ឯកឧត្តម **ស៊ិន ពិសិដ្ឋ** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានលើកឡើងទាក់ទងទៅនឹងកិច្ចការមួយចំនួនដូចតទៅ ៖

- យោងតាមចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ នូវក្នុងរបាយការណ៍បូកសរុប ស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី៦៣ នៃទិវាបុណ្យឯករាជ្យជាតិ០៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ស្នើឱ្យអគ្គលេខាធិការណែនាំមន្ត្រីដែលមានឈ្មោះចាត់ឱ្យចូលរួមពិធីកុំឱ្យមានការខកខានទៀត គឺត្រូវចូលរួមតាមការចាត់តាំង។ បន្ទាប់មកឯកឧត្តមអគ្គលេខាធិការក៏បានចេញលិខិតណែនាំមួយឱ្យឯកឧត្តមអគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងអស់ពិនិត្យមើលចំណាររបស់ឯកឧត្តមប្រធាន និងណែនាំឱ្យ មន្ត្រីក្រោមឱវាទឱ្យគោរពលិខិតឧទ្ទេសនាម លិខិតចាត់តាំង និងការចូលរួមប្រជុំផ្សេងៗទៀត ដែលរៀបចំឡើងដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ករណីអវត្តមានសូមបញ្ជាក់ និងមានឯកសារច្បាស់លាស់ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ។

- ក្រៅពីនោះមានមន្ត្រីមួយចំនួនអវត្តមាននៅក្នុងកិច្ចប្រជុំធំៗ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដូចជា កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ ហើយ នឹងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ជាដើម។
- ឯកឧត្តមប្រធាននាយកដ្ឋាន ក៏បានជម្រាបជូនអង្គប្រជុំអំពីអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ចេញនៅមុនដំណាច់ឆ្នាំ២០១៧ ដែលផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីរាជការ ដូចខាងក្រោម៖

  - ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការពីចំនួន១៧០០រៀល ទៅចំនួន១៩០០រៀល ក្នុងមួយសន្ទស្សន៍ ដែលតម្លៃនេះត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។
  - ការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ និងកូនយោធិននៃកងយោពលខេមរភូមិ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។
  - ការបន្ថែមប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ។
  - ការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា។ ពី៤០ម៉ឺនរៀល ទៅ៥០ម៉ឺនរៀល។



## ២.ការងារបច្ចេកទេស

លោកវេជ្ជ. **ឈា សិទ្ធី** ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានលើកឡើងទាក់ទងទៅនឹងការងារដែលបានអនុវត្តដូចតទៅ ៖

- ស្ថានភាពបុគ្គលិក: លោកវេជ្ជ. ហួត សេរីវដ្ឋ ច្បាប់ (មានជំងឺ)
- នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ខាងមុខនេះនឹងមានកិច្ចប្រជុំក្រុមការងារចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDJ) ដែលដឹកនាំ និងសម្របសម្រួលដោយឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានធ្វើផែនការ ចុះអភិបាលកិច្ចលើកការវិវឌ្ឍន៍រីកចម្រើនក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ នៅឃុំ/សង្កាត់ ឆ្នាំ២០១៧ ក្នុងខេត្តគោលដៅចំនួន០៤ គឺខេត្តបាត់ដំបង ប៉ៃលិន កំពង់ធំ និងខេត្តតាកែវ។

លោកវេជ្ជ. **ទេព ណារុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ បានលើកឡើងទាក់ទងទៅនឹងការងារដែលបានអនុវត្តដូចតទៅ ៖

- ស្ថានភាពបុគ្គលិក មកធ្វើការទៀងទាត់ និងគ្រប់ចំនួន

- កំពុងរៀបចំបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវ
- បានធ្វើរបាយការណ៍ប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន និង បានទទួលផែនសកម្មភាពប្រចាំឆ្នាំ២០១៧ ពីនាយកដ្ឋានចំនួន០២ ដែលបានផ្តល់របាយការណ៍ជូន នៅឡើយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មិនទាន់បានទទួល។
- បានធ្វើរបាយការណ៍ ស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

លោកវេជ្ជ. **វ៉ឹង យ៉ាណាត** ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ បានលើកឡើងទាក់ទងទៅនឹងការងារដែលបានអនុវត្តដូចតទៅ ៖

- ស្ថានភាពបុគ្គលិក មកធ្វើការទៀងទាត់ និងគ្រប់ចំនួន
- បានធ្វើរបាយការណ៍កិច្ចប្រជុំស្តីពីបូកសរុបលទ្ធផលប្រចាំឆ្នាំ២០១៦ និងលើកទិសដៅផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ (MSM)។
- បានបញ្ចប់របាយការណ៍ ស្តីពីការអង្កេតជាតិការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៥ (NASA)។

ឯកឧត្តមឱសថការី **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង ទទួលបន្ទុកនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានផ្តល់យោបល់ និងធ្វើបទបង្ហាញ៖

- មន្ត្រី បុគ្គលិក ដែលបានចាត់តាំងឱ្យទៅចូលរួមក្នុងបុណ្យជាតិ-អន្តរជាតិ និងពិធីផ្សេងៗ ហើយខកខានមិនបានទៅចូលរួមតាមការចាត់តាំង ទទួលខុសត្រូវដូចដែលមានចែងក្នុងច្បាប់ ស្តីពីសហលក្ខន្តិកៈរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។
- នាយកដ្ឋានដែលខ្វះមន្ត្រីធ្វើការ ធ្វើលិខិតស្នើសុំមកថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងសម្រេច។
- រាល់ទម្រង់នៃលិខិតរដ្ឋបាលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមានការកែប្រែឱ្យបានល្អប្រសើរជាងនេះ។

❖ **បទបង្ហាញ៖**

- លិខិតរដ្ឋបាល

  ១. ប្រភេទលិខិតរដ្ឋបាល

  ២.ទម្រង់លិខិតរដ្ឋបាល

  ៣.និងលិខិតស្នើផ្សេងៗ។



ឯកឧត្តមប្រធានអង្គប្រជុំបានណែនាំដូចខាងក្រោម ៖

១.ស្នើឱ្យការិយាល័យបុគ្គលិក និងបៀវត្សពលកម្មនៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវតែលើកអំពីការអវត្តមានរបស់មន្ត្រី បុគ្គលិកនៅរាល់កិច្ចប្រជុំប្រចាំខែ ហើយរៀបចំលើកទឹកចិត្តមន្ត្រី បុគ្គលិកឆ្នើមប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៧នេះ។

២.ស្នើឱ្យប្រធាននាយកដ្ឋាននីមួយៗ ត្រូវតែពិនិត្យឡើងវិញ អំពីបញ្ជីវត្តមានរបស់មន្ត្រីខ្លួន ហើយប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះបញ្ហានេះ។

៣.គ្រប់នាយកដ្ឋានទាំងអស់ ដែលខ្វះមន្ត្រីធ្វើការងារត្រូវធ្វើលិខិតស្នើសុំមកឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច។

៤.ស្នើឱ្យប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវមានកិច្ចប្រជុំជាទៀងទាត់ជាមួយមន្ត្រីជាប់កិច្ចសន្យា និងធ្វើកំណត់ហេតុរបាយការណ៍ ជូនអគ្គលេខាធិការ។

៥.ស្នើឱ្យប្រធាននាយកដ្ឋាននីមួយៗ ដែលមានមន្ត្រីចុះបំពេញបេសកកម្មចំថ្ងៃនៃកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន ត្រូវមានការចាត់តាំងមន្ត្រីរបស់ខ្លួន ចូលរួម និងធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំ។

៦.ស្នើឱ្យមន្ត្រីដែលត្រូវបានឧទ្ទេសនាមឱ្យទៅចូលរួមបុណ្យជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ត្រូវតែបំពេញកាតព្វកិច្ចនេះ ព្រោះកន្លងមកមានមន្ត្រី ដែលមានឧទ្ទេសនាម តែមិនបានចូលរួម និងជៀសវាងចូលរួមហើយមិនបានពេញលេញ។

៧.ស្នើឱ្យប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវតែធ្វើការចាត់តាំងអគារអនុរក្ស ឬវេនយាម នៅបណ្ណាល័យ និងនៅកន្លែងទទួលភ្ញៀវ។

៨.នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវពិនិត្យមើល ចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ដោយយោងទៅលើក លិខិតរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ ដើម្បីឱ្យការអនុវត្តនេះមានប្រសិទ្ធភាព។

៩.មន្ត្រីទាំងអស់ ដែលអវត្តមាន ឬខកខានមិនបានសុំច្បាប់តាមបែបបទរដ្ឋបាល អាចទាក់ទងឬហៅទូរស័ព្ទមកកាន់អគ្គលេខាធិការ (ក្នុងករណីចាំបាច់)។

១០.នាយកដ្ឋាននីមួយៗត្រូវធ្វើគម្រោងផែនការប្រចាំឆ្នាំ២០១៧ ដើម្បីអនុវត្ត និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

១១.មន្ត្រីជាប់កិច្ចសន្យាដែលមាននៅក្នុងលិខិតចាត់តាំងឱ្យប្រចាំការ នៅក្នុងបណ្ណាល័យ មុនពេលចេញ-ចូលត្រូវរៀបចំទុកដាក់ឯកសារ ឬសៀវភៅ និងសម្ភារប្រើប្រាស់ឱ្យមានរបៀបរៀបរយ។

១២.ស្នើឱ្យនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ពិនិត្យមើលចំណតឡានខាងក្រោមអគារក្រៅពីឡានរបស់មន្ត្រី បុគ្គលិក មិនត្រូវឱ្យមានឡាន ឬរទេះ ឬម៉ូតកង់បីដាក់ក្នុងម៉ោងធ្វើការឡើយ។

១៣.ស្នើឱ្យឯកឧត្តមវេជ្ជ. ជា ប៉ោ ធ្វើផែនការកម្មវិធីនៃកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៧ និង បែងចែកតួនាទីភារកិច្ចទទួលខុសត្រូវ មន្ត្រីរបស់ខ្លួន និងធ្វើរបាយការណ៍។

១៤.ស្នើឱ្យឯកឧត្តមវេជ្ជ. **ស៊ឹម គឹមសាន** សម្របសម្រួលក្នុងកិច្ចប្រជុំក្រុមការងារចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (GDJ)។

១៥.មន្ត្រីទាំងអស់ ត្រូវតែផ្តល់តម្លៃ និងកិត្តិយសឱ្យគ្នាទៅវិញទៅមក នូវរាល់ការចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗតាមការចាត់តាំង ឬឧទ្ទេសនាម។

១៦.ស្នើឱ្យមន្ត្រីទាំងអស់ ត្រូវរឹតចំណងសាមគ្គីភាពគ្នាក្នុងពេលបំពេញការងារ ។ ត្រូវអនុវត្តការងារដោយផ្អែកលើរចនាសម្ព័ន្ធ គោលការណ៍ណែនាំរបស់ស្ថាប័ន ដើម្បីជៀសវាងការថ្នាំងថ្នាក់រវាងបុគ្គល នឹងបុគ្គលនៅពេលដែលយើងមិនបានយល់ច្បាស់ ពីខ្លឹមសារការណែនាំទាំងនេះ ។

១៧.មន្ត្រី បុគ្គលិកទាំងអស់ ត្រូវចេះយោគយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមកទាំងក្នុងពេលបំពេញកាងារ និងសាមគ្គីភាពផ្ទៃក្នុងជាមហាគ្រួសារតែមួយ។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានក្រើនរំលឹកផងដែរ ជាពិសេសដល់ថ្នាក់ដឹកនាំនាយកដ្ឋាន ត្រូវចេះមើលឱ្យបានទូលំទូលាយ ចែករំលែកការងារ ជួយមន្ត្រីដែលនៅមានចំណុចខ្វះខាត ដើម្បីឱ្យបានល្អទៅមុខ និងលើកទឹកចិត្តមន្ត្រីដែលបានខិតខំបំពេញការងារ

១៧.មន្ត្រី បុគ្គលិកទាំងអស់ ត្រូវចេះយោគយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមកទាំងក្នុងពេលបំពេញកាងារ និងសាមគ្គីភាពផ្ទៃក្នុងជាមហាគ្រួសារតែមួយ។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានក្រើនរំលឹកផងដែរ ជាពិសេសដល់ថ្នាក់ដឹកនាំនាយកដ្ឋាន ត្រូវចេះមើលឱ្យបានទូលំទូលាយ ចែករំលែកការងារ ជួយមន្ត្រីដែលនៅមានចំណុចខ្វះខាត ដើម្បីឱ្យបានល្អទៅមុខ និងលើកទឹកចិត្តមន្ត្រីដែលបានខិតខំបំពេញការងារ ជៀសវាងការស្តីបន្ទោសនៅពេលដែលយើងមិនទាន់បានណែនាំបង្រៀនគ្នា។ ត្រូវចាត់ទុកមន្ត្រីសហការី ដូចជាបងប្អូនក្នុងការអនុវត្តការងារ។ ឯកឧត្តមក៏បានបញ្ជាក់ និងដាស់តឿនផងដែរ នូវការពង្រឹងសាមគ្គីភាព ការសហការអនុវត្តការងារប្រចាំថ្ងៃ និងត្រូវកែសម្រួលរាល់ចំណុចខ្វះខាតដើម្បីបង្កើនសមត្ថភាពខ្លួនឯង ។



អង្គប្រជុំបានបញ្ចប់ នៅវេលាម៉ោង១១ និង៣០នាទីនាថ្ងៃខែឆ្នាំដដែលប្រកបដោយភាពរីករាយ។

អ្នកធ្វើរបាយការណ៍

ណែម សុខលី

បានឃើញ និង ឯកភាព
ប្រធានអង្គប្រជុំ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

16-1-17



Scanned by CamScanner